# ល្ខោនមហោរី

បើយើងពិនិត្យឱ្យមែនទែនទៅសិល្បៈទស្សនីយភាពរបស់ខ្មែរ គឺមានភាពសម្បូណ៌បែបណាស់ដែលអ្នកស្រាវជ្រាវបានចងក្រងទុកជាឯកសារ សម្រាប់អ្នកស្រាវជ្រាវជំនាន់ក្រោយនិងជាពិសេសសម្រាប់ក្មេងៗទុកជាចំណេះដឹង តួយ៉ាងដូចជាតន្ត្រី អាយ៉ៃ ចម្រៀងចាប៉ី ចាប៉ីរឿង និទានរឿង របាំ និងល្ខោន ជាដើមៗ នៅទីនេះ ខ្ញុំសូមលើកយកតែល្ខោនមហោរីមកអធិប្បាយតែប៉ុណ្ណោះៗ

យើងចាត់ទុក «ល្ខោនមហោរី» ជាទម្រង់ល្ខោនច្រៀងរាំ នៃប្រទេសកម្ពុជាកំដរដោយវង់តន្ត្រីមហោរី ដែលមានឧបករណ៍ រនាតឯក រនាតធុង ទ្រខ្មែ ទ្រសោតូច ទ្រសោធំ ទ្រអ៊ូ ខ្លុយ ឃឹម ក្រពើ ថូន រមនា ឈឹង និងអ្នកច្រៀងៗ[១] ឧបករណ៍នៅក្នុងវង់តន្ត្រីមហោរីសម្រាប់កំដរល្ខោនមហោរីអាចមានច្រើនឬតិចទៅតាមលទ្ធភាពចំណង់ចំណូលចិត្ត និងតម្រូវការៗ វង់តន្ត្រីមហោរី ជាវង់តន្ត្រីដែលមានចរិតលក្ខណៈនិងសូរស្រាលដែលគេច្រើនយកទៅប្រើកំដរពិធីជប់លៀង ជួបជុំកែកម្សាន្ត របាំប្រពៃណីខ្មែរនិងល្ខោនមហោរីៗ ចំពោះអ្នករាំឬសម្ដែងល្ខោនមហោរី ខ្លះរាំផង ច្រៀងផង និងនិយាយផងៗ

ឯកសារស្រាវជ្រាវមួយចំនួនបានអះអាងថា "**ល្ខោនមហោរី**" មានអាយុកាលជាយូរយារណាស់មកហើយ ដូចជាទម្រង់សិល្បៈទស្សនីយភាពឯទៀត មានល្ខោនយីកេ និងបាសាក់ជាដើមៗ[២] ក្រោយពីសាលារចនា បានប្ដូរទៅជាសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈនៅឆ្នាំ១៩៦៥ ដែលរៀបចំដោយលោក វណ្ណ ម៉ូលីវណ្ណ ទម្រង់ល្ខោនមហោរីនេះក៏មានឱកាសបានរំឭកនិងរំលេចឡើងវិញ ដោយបានបញ្ចូលទៅក្នុងកម្មវិធីសិក្សាឱ្យសិស្សរៀន ព្រមទាំងបង្កើតនិងតម្លើងជាស្នាដៃ មានដូចជារឿងថ្មរាំនិងវិប្បដិសារីនៃព្រានព្រៃជាដើមៗ[៣]

រឿងនិងស្នាដៃដែលបានបង្កើតនិងតម្លើងក្នុងទម្រង់ល្ខោនមហោរី មានជាអាទិគឺ៖ រឿងវិប្បដិសារីនៃព្រានព្រៃ និពន្ធដោយលោក ពេជ្រ ទុំក្រវិល

---

[១] https://ams.com.kh/khmercivilization/detail/2905

[២] ពេជ្រ ទុំក្រវិល ២០០៣: ១៧១

[៣] ពេជ្រ ទុំក្រវិល ២០០៣: ១៧២-១៧៣

អត្ថបទដោយ៖

រឿងប្រហែសបាត់ប្រយ័ត្នគង់ និពន្ធដោយលោក ពេជ្រ ទុំក្រវិល
រឿងមិនខ្វះទេអ្នកស្រឡាញ់យុត្តិធម៌ និពន្ធដោយលោក ពេជ្រ ទុំក្រវិល
រឿងតេមិយកុមារ តម្លើងដោយលោក ពេជ្រ ទុំក្រវិល
រឿងសុវណ្ណសាម តម្លើងដោយលោក ពេជ្រ ទុំក្រវិល
និងរឿងខ្វះមួយចំនួនទៀត និពន្ធដោយសាស្ត្រាចារ្យនិងសិល្បករសិល្បការិនីនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។

បច្ចុប្បន្ន "**ល្ខោនមហោរី**" ក៏នៅមានប្រជាប្រិយភាពដែរ ប៉ុន្តែត្រូវប្រឈមនឹងការប្រកួតប្រជែងជាមួយនឹងសិល្បៈដទៃទៀត ជាពិសេសសិល្បៈកែកម្សាន្តសម័យទំនើបតាមរយៈបច្ចេកវិទ្យាថ្មីនិងគុណភាពខ្ពស់ ដែលធ្វើឱ្យល្ខោនមហោរី ក៏ដូចជាទម្រង់សិល្បៈប្រពៃណីឯទៀតៗដែរ គឺមានការលំបាកខ្លាំងក្នុងការធ្វើឱ្យមាននិរន្តរភាពនិងការពេញនិយមឡើងវិញពីមហាជន។ នេះជាការព្រួយបារម្ភណាស់ ចំពោះទម្រង់សិល្បៈប្រពៃណីខ្មែរដ៏ល្អផូរផង់ រួមទាំងល្ខោនមហោរី ដ្បិតអីទម្រង់សិល្បៈទាំងអស់នេះ ជាទ្រព្យដ៏ពិសិដ្ឋរបស់ដូនតាបានបន្សល់ទុកឱ្យខ្មែរជំនាន់ក្រោយ។ តែបើគ្មានការរៀនសូត្រ យល់ដឹង ស្រឡាញ់ គាំទ្រ បណ្ដុះបណ្ដាល ថែរក្សា លើកស្ទួយ និងផ្សព្វផ្សាយជាកម្មវិធីសិល្បៈវប្បធម៌ប្រក្រតីតាមរយៈកម្មវិធីសិល្បៈសាធារណៈ កម្មវិធីសិក្សា និងតាមបណ្ដាញផ្សព្វផ្សាយនានាក្នុងគោលបំណងនិងគោលដៅបំផុសបំផុលពញ្ញាក់ស្មារតី ក្នុងចំណោម និងស្រទាប់យុវជន យុវនារី និងប្រជាពលរដ្ឋខ្មែរទេ ទម្រង់សិល្បៈប្រពៃណីទាំងនេះនឹងប្រឈមទៅនឹងការបាត់បង់ឬធ្លាក់ចុះនាពេលអនាគតជាក់ជាពុំខាន។

អត្ថបទដោយ៖

# ការសម្តែងល្ខោនមហោរី







ប្រភពរូបភាព៖ អត្ថបទទម្រង់សិល្បៈមហោរីខ្មែរ និពន្ធដោយលោកស្រី យ៉ាន់វិការតន៍

អត្ថបទដោយ៖

## ឯកសារយោង

ពេជ្រ ទុំក្រវិល.

២០០៣. *ទស្សនីយភាពខ្មែរ*. ភ្នំពេញ: រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

https://ams.com.kh/khmercivilization/detail/2905